# ជម្ងឺមហារីកថ្លើម

កោសិកាមហារីកបែប ហិបប៉ាថូសែលឡូឡា (Hepatocellular Carcinoma)


Esophagus
Liver
Stomach
Gallbladder
Colon
Small
Intestine
Rectum

# តើជម្ងឺមហារីកថ្លើមគឺជាអ្វី?

- វាគឺជាជម្ងឺមហារីកដ៏សាមញ្ញមួយ កើតមកពីកោសិកាថ្លើមដែលសំខាន់ជាងគេ ហៅថា ៖ Hepatocyte ។
- ក្នុងចំណោមជម្ងឺមហារីកថ្លើមខ្លាំងជាងគេបួន មានបីជាមហារីកប្រភេទ Hepatocellular ។
- ជម្ងឺមហារីកថង់ប្រមាត់ (Cholangio Carcinoma) ចាប់ផ្តើមពីបំពង់ទឹកប្រមាត់តូច ដែលនាំទឹកប្រមាត់ទៅក្នុងថង់ប្រមាត់។
- ក្នុងចំណោមជម្ងឺមហារីកថ្លើម១០ មានប្រហែលមួយ ឬពីរជាមហារីកប្រភេទ Cholangio ។

# តើមានមនុស្សប៉ុន្មាននាក់ ដែលកើតជម្ងឺមហារីកថ្លើម?

- នៅសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៤ មានមនុស្សចំនួន ១៨,៩២០ នាក់ កើតជម្ងឺមហារីកថ្លើម និងមហារីកថង់ប្រមាត់។
- មនុស្សចំនួន ១២,៤៧០នាក់ នឹងត្រូវស្លាប់ដោយសារជម្ងឺមហារីកថ្លើម។
- បុរសកើតជម្ងឺមហារីកច្រើនជាងស្ត្រីមួយទ្វេរជាពីរ។
- ជាទូរទៅ នៅសហរដ្ឋអាមេរិក ជម្ងឺមហារីកថ្លើមគឺជាមហារីកទី១៤ ។
- នៅក្នុងសង្គមខ្មែរ ជម្ងឺមហារីកថ្លើមគឺជាមហារីកទី ១។



Lung and Bronchus
Stomach
Colon and Rectum
Prostate
Pancreas
Liver
Leukemia
Rate per 100,000 Males
0
20
40
60
80
100
1930
1932
1934
1936
1938
1940
1942
1944
1946
1948
1950
1952
1954
1956
1958
1960
1962
1964
1966
1968
1970
1972
1974
1976
1978
1980
1982
1984
1986
1988
1990
1992
1994
1996
1998
2000

# តើជម្ងឺមហារីកថ្លើមបណ្ដាលមកពីអ្វី?

ជម្ងឺមហារីកថ្លើមបណ្ដាលមកពី ៖

- ជំងឺរលាកថ្លើមរ៉ាំរ៉ៃប្រភេទ បេ (HBV) និងសេ (HCV)។
- ជម្ងឺក្រិនថ្លើមដែលបណ្ដាលមកពីការពិសារស្រា ជំងឺរលាកថ្លើម ឬក៏មាន ជាតិដែកនៅក្នុងថ្លើមច្រើនពេក។
- ការជក់បារី។
- និងសណ្ដែកដី ស្រូវសាលី ពោត សណ្ដែកសៀង និង អង្ករ ដែលដុះផ្សិត បង្កើតជាតិពុល Aflatoxins ។

# តើជម្ងឺមហារីកថ្លើមអាចការពារបាន ឬទេ?

ការចម្លងមេរោគជំងឺថ្លើមប្រភេទ បី :

- ជម្ងឺជំងឺថ្លើមប្រភេទបី មាននៅក្នុងឈាម និងវត្ថុរាវដែលនៅក្នុងរាងកាយយើងដូចជា : ទឹកមាត់ ទឹកកាម ទឹករំអិលនៅក្នុងយោនី និងទឹកដោះ។
- ជម្ងឺជំងឺថ្លើមអាចឆ្លងនៅពេលសេពកាម និងប្រើម្ជុលចាក់ថ្នាំប្រចាសផុះផ្ទេញ កាំបិតកោរ និងឡាមកោរជាមួយគ្នា។
- ជម្ងឺជំងឺថ្លើមនេះ អាចឆ្លងពីម្តាយទៅទារក នៅពេលដែលសំរាលកូន។

# តើជម្ងឺមហារីកថ្លើមអាចការពារបាន ឬទេ? (ត...)

វិធីកាត់បន្ថយការឆ្លងជម្ងឺដំបៅថ្លើមប្រភេទ បី ៖

- ត្រូវលាងដៃបន្ទាប់ពីប្រឡាក់ឈាម ឬប៉ះនឹងវត្ថុរាវនៅក្នុងរាងកាយ។
- ត្រូវជាសវាងប្រើរបស់ផ្ទាល់ខ្លួន ឬរបស់អ្នកដទៃដែលជាប់វត្ថុរាវក្នុងរាង កាយ។
- បើមានរបួស ឬដំបៅ ត្រូវបិតបង់រុំរបួស (Band Aid) ឲ្យជិត។
- ត្រូវប្រើស្រោម ឬវិធីការពារនៅពេលរួមដំណេក។

# តើជម្ងឺមហារីកថ្លើមអាចការពារបាន ឬទេ? (ត...)

ចាក់ថ្នាំការពារជម្ងឺដំបៅថ្លើមប្រភេទបី មាន :

- សំរាប់ក្មេងទាំងអស់
- សំរាប់មនុស្សចាស់ដែលអាចមានគ្រោះថ្នាក់ ដោយសារជម្ងឺមហារីក។
- ជាសវាងកុំទទួលទានស្រាច្រើនហួសប្រមាណ។
- យើងមិនទាន់មានថ្នាំសម្រាប់ការពារជម្ងឺដំបៅថ្លើមប្រភេទស៊ី (C) ទេ។

# តើគេអាចជាសះស្បើយពីជម្ងឺមហារីកថ្លើមបានដែរឬទេ? (ត...)

ការឆ្លងជម្ងឺដំបៅថ្លើមប្រភេទ សុី :

- ឆ្លងតាមឈាមនឹងឈាម
- ឆ្លងតាមការចាក់ម្ជុលមិនស្អាត និងម្ជុលចាក់សាក់ ការចោះពាក់ក្រវិល ប្រើឡាម ឬកាំបិតកោរនិងប្រើច្រាសដុះធ្មេញជាមួយគ្នា។
- ការរួមដំណេកខុសរបៀប
- ឆ្លងពីម្តាយទៅទារក

# តើយើងអាចពិនិត្យឃើញជម្ងឺមហារីកថ្លើមដោយរបៀបណា?

រោគសញ្ញា ៖

- មិនឃ្លានអាហារ និងស្រកទម្ងន់
- ស្បែកនិងភ្នែកប្រែជាមានពណ៌លឿង
- ពោះហើមប៉ោងធំ
- ឈឺនៅក្នុងពោះ

# តើយើងអាចធ្វើរោគវិនិច្ឆ័យជម្ងឺមហារីកថ្លើមដោយរបៀបណា?

ការធ្វើតែស្ត :

- ត្រូវពិនិត្យឈាម ដើម្បីមើលការធ្វើការរបស់ថ្លើម។
- ការយកឈាមទៅពិនិត្យរបៀប អាល់ហ្វា-ហ្វីតូប្រូតេអ៊ិន (Alpha Fetoprotein) ។
- ត្រូវយកឈាមទៅពិនិត្យមើលជម្ងឺរលាកថ្លើមប្រភេទ បី និងស៊ី។

# តើយើងអាចធ្វើរោគវិនិច្ឆ័យជម្ងឺមហារីកថ្លើមដោយរបៀបណា? (ត...)

ការធ្វើតែស្ត

- អល់ត្រាសោន (Utrasound)
- ថតមើលថ្លើមដោយ ស៊ី-ធី-ស្កែន (TC Scan) និង អិម-អ័រ-អាយ-ស្កែន (MRI) ។
- ច្រឹបសាច់យកទៅពិនិត្យ (Biopsy) ។
- ថតមើលថ្លើមដោយម៉ាស៊ីន អែងជីអូក្រាម (Angiogram) ។
- ការពិនិត្យថ្លើមដោយប្រើបំពង់ស៊កចូលទៅខាងក្នុង (Laparoscopy) ។

# ដំណាក់ការនៃជម្ងឺមហារីកថ្លើម

- ដំណាក់ការទី ១ សាច់ដុះមានទំហំតូចជាង ២ សង្ទីម៉ែត្រ
- ដំណាក់ការទី ២ សាច់ដុះធំតែមួយដែលមានមហារីក ឬសាច់ដុះតូចៗផ្តុំគ្នា ជាច្រើន នៅលើចុងទងម្ខាងនៃថ្លើម។
- ដំណាក់ការទី ៣ មានមហារីកដុះធំៗ នៅលើចុងទងម្ខាងនៃថ្លើម ឬមហារីកថ្លើមបានឆ្លងទៅតាមសសៃទឹករងៃ។
- ដំណាក់ការទី ៤ មហារីកថ្លើមបានឆ្លងទៅទងថ្លើមទាំងសងខាង។

# ការព្យាបាលជម្ងឺមហារីកថ្លើម :

- ការវះកាត់
- ការព្យាបាលជម្ងឺក្នុងបំណងឲ្យជាសះស្បើយ នៅដំណាក់ការទី១ និងទី២។
- ការកាត់ថ្លើមដែលកើតមហារីកមួយដុំចេញ
- ការកាត់ចុងទងថ្លើមដែលមានមហារីកចេញ
- ការប្តូរថ្លើម

# ការព្យាបាលជម្ងឺមហារីកថ្លើម (ត...) ៖

- ការព្យាបាលដោយប្រើគីមី (ធ្វើគីម៉ូតេរាពី)
- ការព្យាបាលដោយដាក់ថ្នាំបញ្ចូលតាមសរសៃឈាមធំ។
- ការដាក់ថ្នាំគីមីទប់ស្កាត់កុំឲ្យវាបែកខ្ញែកទៅកន្លែងផ្សេងៗទៀត។

# ការព្យាបាលជម្ងឺមហារីកថ្លើមដោយប្រើគីមី (ត...) :

- ប្រតិកម្មនៃការព្យាបាល
- ធ្វើឲ្យរម្ងួលពោះ និងក្អួតចង្អោរ
- មិនសូវឃ្លានអាហារ
- ជ្រុះសក់មួយរយៈ
- ពងមាត់ ឬពងនៅក្នុងយោនី
- ការងាយស្រួលធ្វើឲ្យមានដំបៅរលាក ឬក្លាយ
- ចេញឈាមនៅពេលមានរបួសបន្តិចបន្តួច
- ខ្វះឈាមក្រហម និងធ្វើឲ្យឈាមចុះ
- ការអស់កម្លាំង

# ការព្យាបាលជម្ងឺមហារីកថ្លើម (ត...) :

- វិធីព្យាបាលដោយប្រើកាំរស្មីបញ្ចាំងផ្នែកខាងក្រៅ មិនសូវបានប្រើការទេ។
- ការទប់ស្កាត់ជម្ងឺដោយប្រើ រេឌីអូហ្វ្រេហ្វិខ្វិនស៊ី អាប់ប្លេសិន (Radiofrequency Ablation)។
- ការព្យាបាលដោយប្រើសីតុណ្ហភាពទាប (Cryotherapy)។

# ជម្ងឺមហារីកថ្លើម ៖

អ្នកជម្ងឺអាចរស់បានប្រាំឆ្នាំ ៖

- ក្នុងចំណោមអ្នកជម្ងឺដែលកើតរោគមហារីកថ្លើមនៅតែមួយកន្លែង ហើយពិនិត្យឃើញនៅពេលវាទើបតែចាប់ផ្តើម មាន ៣០ទៅ៤០%។
- ក្នុងចំណោមអ្នកជម្ងឺគ្រប់ដំណាក់ការទាំងអស់ មាន ១០%។

# កោសិកាដែលធ្វើឲ្យកើតមហារីកថ្លើម ៖

- វាគឺជាមូលហេតុទីមួយដែលបណ្តាលឲ្យជនជាតិអាស៊ីស្លាប់។
- ជម្ងឺមហារីកថ្លើមច្រើនតែកើតឡើងចំពោះជនជាតិខ្មែរ វៀតណាម កូរេ និងចិន។
- ទំនាក់ទំនងរវាងជម្ងឺដំបៅថ្លើមប្រភេទ ប៊ី និង ស៊ី
- ទារកនិងក្មេងទាំងអស់នៅក្នុងសហរដ្ឋអាមេរិក ត្រូវចាក់ថ្នាំបង្ការរោគថ្លើមប្រភេទ ប៊ី។

# សូមអរគុណ!

សូមអរគុណ ដែលលោកអ្នកបានប្រើកម្មវិធីបង្រៀនអំពីជម្ងឺមហារីករបស់ Refugee and Immigrant Health Promotion Project នៃមន្ទីរពេទ្យ Harborview កម្មវិធីនេះ ឧបត្ថម្ភដោយ AANCART យើងខ្ញុំសូមអភ័យទោសពីសំណាក់លោកនិងលោកស្រី ចំពោះការខ្វះខាត ឬខុសឆ្គងទាំង អស់ ដែលមាននៅក្នុងកម្មវិធីនេះ។ សូមអរគុណ

# References:


American Gastroenterological Association (http://www.gastro.org/public/drdan-colc.html)

American Cancer Society www.cancer.org

National Cancer Institute’s Cancer Information Service (http://cancernet.nci.nih.gov)

Harvard Center for Cancer Prevention (www.yourcancerrisk.harvard.edu)